# ថ្នាំបង្ការ

## ហេតុអ្វីបានជាថ្នាំបង្ការទាំងឡាយមានសារៈសំខាន់?








### ការចាក់ថ្នាំបង្ការគឺជាវិធីដែលមានសុវត្ថិភាព មានប្រសិទ្ធិភាពយ៉ាងខ្លាំង និងមានភាពងាយស្រួលមួយដើម្បីៈ

- ការពារខ្លួនអ្នកផ្ទាល់ពីរោគផ្សេងៗ និងការកើតជំងឺកម្រិតធ្ងន់ធ្ងរ។
- ទប់ស្កាត់អ្នកពីការសាយភាយជំងឺផ្សេងៗទៅកាន់អ្នកដទៃដែលប្រហែលជាអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ដូចជាមនុស្សចាស់ អ្នកដែលមានប្រព័ន្ធភាពស៊ាំទន់ខ្សោយ អ្នកដែលមានផ្ទៃពោះ និងអ្នកដែលមិនអាចចាក់ថ្នាំបង្ការបាន រួមមានទាំងទារកនៅក្នុងករណីមួយចំនួន ផងដែរ។

### តើនរណាខ្លះត្រូវការថ្នាំបង្ការ?

- មនុស្សគ្រប់រូបអាចទទួលបានអត្ថប្រយោជន៍ពីថ្នាំបង្ការបាន ចាប់ពីទារកទើបនឹងកើត រហូតដល់មនុស្សពេញវ័យ។
- មានការណែនាំឱ្យចាក់ថ្នាំបង្ការទាំងឡាយដោយផ្អែកទៅលើអាយុ និងស្ថានភាពសុខភាពរបស់អ្នក ហើយអ្នកអាចនឹងត្រូវការថ្នាំបង្ការសម្រាប់ចូលសាលារៀន ទៅធ្វើការ ធ្វើដំណើរ ឬចូលទីតាំងថែទាំកុមារ ផងដែរ។
- សម្រាប់កម្រិតការពារដែលល្អបំផុត ការធ្វើឱ្យថ្នាំបង្ការទាំងឡាយបានគ្រប់លក្ខណៈនិងទាន់ពេលវេលាដោយការទទួលចាក់ថ្នាំបង្ការឱ្យបានគ្រប់ចំនួនដូសដែលបានណែនាំទាំងអស់ គឺជាការចាំបាច់។



ដើម្បីស្វែងយល់ថាតើថ្នាំបង្ការណាខ្លះដែលមានការណែនាំសម្រាប់ឱ្យអ្នកចាក់នោះ សូមសាកសួរទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាព ឬឱសថការី (អ្នកលក់ថ្នាំពេទ្យ) របស់អ្នក។ សម្រាប់បញ្ជីថ្នាំបង្ការដែលមានការណែនាំឱ្យទទួលចាក់ទាំងឡាយ សូមចូលទៅកាន់គេហទំព័រៈ https://www.cdc.gov/vaccines។

### តើថ្នាំបង្ការទាំងឡាយដំណើរការយ៉ាងដូចម្តេច?

- ថ្នាំបង្ការទាំងឡាយបង្រៀនរាងកាយរបស់អ្នកឱ្យស្គាល់មេរោគជំងឺ (viruses) ឬមេរោគរស់ (bacteria) ដែលបង្កគ្រោះថ្នាក់ ហើយផលិតអង់ទីគ័រពិសេសដើម្បីរក្សាឱ្យអ្នកនៅតែមានសុខភាពល្អ ប្រសិនបើអ្នកឆ្លងមេរោគនៅថ្ងៃណាមួយ។
- ថ្នាំបង្ការទាំងឡាយមានច្រើនប្រភេទ ហើយអាចផ្តល់ជូនបានជាការចាក់តាមម្ជុល ជាការលេបតាមមាត់ ឬជាការបាញ់តាមច្រមុះ។
- ចំណុចជាច្រើនអាចប៉ះពាល់ទៅលើកម្រិតការពារដែលថ្នាំបង្ការផ្តល់ឱ្យ រួមមានបរិមាណនៃការប៉ះពាល់ទៅនឹងមេរោគឆ្លង ពេលវេលាចាប់តាំងពីការទទួលចាក់ថ្នាំបង្ការ និងកត្តាសុខភាពផ្ទាល់ខ្លួនជាដើម។ បើទោះបីជាមិនមានថ្នាំបង្ការណាដែលល្អឥតខ្ចោះ 100% ទេនោះ ក៏ប៉ុន្តែថ្នាំបង្ការគឺជាវិធីល្អបំផុតដើម្បីការពារអ្នកពីការកើតជំងឺកម្រិតធ្ងន់ធ្ងរ។

County of Los Angeles Public Health

# ថ្នាំបង្ការ

## ហេតុអ្វីបានជាថ្នាំបង្ការទាំងឡាយមានសារៈសំខាន់?








## តើពួកយើងដឹងថាថ្នាំបង្ការទាំងឡាយគឺមានសុវត្ថិភាព បានយ៉ាងដូចម្តេច?

- មុនពេលថ្នាំបង្ការថ្មីណាមួយមានសម្រាប់ឱ្យសាធារណជនប្រើប្រាស់នោះ មានការធ្វើតេស្តយ៉ាងច្រើន ដើម្បីឱ្យដឹងថាថ្នាំបង្ការនោះមានសុវត្ថិភាព និងមានផ្តល់កម្រិតការពារច្រើនគួរឱ្យកត់សម្គាល់ជាង ប្រសិនបើមនុស្សម្នាក់នោះមិនមានចាក់ថ្នាំបង្ការអ្វីសោះ។
- ទីភ្នាក់ងាររដ្ឋាភិបាលនានាអនុម័តឱ្យប្រើប្រាស់ថ្នាំបង្ការថ្មីៗ ហើយតាមដានមើលវិធីប្រើប្រាស់ ព្រមទាំងផលប៉ះពាល់និងប្រសិទ្ធិភាពរបស់ថ្នាំបង្ការ ដោយធ្វើការផ្លាស់ប្តូរនានាទៅតាមការចាំបាច់។
- ការស្រាវជ្រាវដ៏ធំធេងដោយអ្នកវិទ្យាសាស្ត្រ មន្ទីរពេទ្យ និងមហាវិទ្យាល័យផ្សេងៗបានលាតត្រដាងចំណុចមិនពិតនៃជំនឿតៗគ្នា និងព័ត៌មានមិនត្រឹមត្រូវអំពីថ្នាំបង្ការ។ មិនមានការទាក់ទងរវាងថ្នាំបង្ការទាំងឡាយ និងបញ្ហាការលូតលាស់ផ្នែកយល់ដឹង (autism) ឬការមិនមានកូនឡើយ ហើយថ្នាំបង្ការក៏មិនកែប្រែ DNA ឬបណ្តាលឱ្យមានជំងឺនោះទេ។

## ហេតុអ្វីបានជាខ្ញុំអាចមានអារម្មណ៍មិនសូវស្រួលខ្លួន បន្ទាប់ពីការទទួលចាក់ថ្នាំបង្ការរួច?

- ដូចគ្នាទៅនឹងថ្នាំពេទ្យផងដែរនោះ ថ្នាំបង្ការទាំងឡាយអាចមានផលប៉ះពាល់ផ្សេងៗ ដូចជាគ្រុនក្តៅ អស់កម្លាំង ឈឺក្បាល និងការឡើងហើមនៅនឹងកន្លែងដែលទទួលថ្នាំបង្ការនោះ។
- ផលប៉ះពាល់ទាំងនេះបង្ហាញថារាងកាយរបស់អ្នកគឺកំពុងតែបង្កើតប្រព័ន្ធការពារប្រឆាំងនឹងមេរោគនោះ។
- មនុស្សភាគច្រើនត្រឹមតែកើតមានផលប៉ះពាល់កម្រិតស្រាលប៉ុណ្ណោះ ឬមិនកើតមានអ្វីទាំងអស់។ ជាធម្មតា ផលប៉ះពាល់ផ្សេងៗបាត់ទៅវិញដោយខ្លួនឯង ក្នុងអំឡុងពេលពីរឬបីថ្ងៃក្រោយមក។
- ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរគឺកម្រនឹងកើតមាន។ ប្រសិនបើផលប៉ះពាល់ផ្សេងៗកាន់តែធ្ងន់ធ្ងរទៅ បង្កការព្រួយបារម្ភដល់ ឬកើតមានច្រើនជាងពីរថ្ងៃនោះ សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក។



### មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Call Center)

សម្រាប់ព័ត៌មានបន្ថែម មជ្ឈមណ្ឌលផ្តល់ព័ត៌មានរបស់នាយកដ្ឋានសុខភាពសាធារណៈ មានបម្រើសេវាកម្មជូនចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8 យប់ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈលេខ **1-833-540-0473**។



COUNTY OF LOS ANGELES
**Public Health**